# ការកសាងផែនការយុទ្ធសាស្ត្រ

ដោយ ឡេងឆាយ

## ការកសាងផែនការយុទ្ធសាស្ត្រជាអ្វី?

- ជាដំណើរការមួយ ដើម្បីកំនត់នូវអ្វីដែលស្ថាប័នអ្នកចង់បាននាពេលអនាគត ហើយធ្វើការសំរេចចិត្តអំពីវិធីផ្សេងៗ ដើម្បីឈានទៅសំរេចគោលបំណងនោះ។
- ជាដំណើរការស្វែងរក និងកំនត់បញ្ហាយុទ្ធសាស្ត្ររបស់អង្គការ ហើយលើកយុទ្ធសាស្ត្រសមស្របដើម្បីដោះស្រាយ។
- មានន័យលើសពីផែនការរយៈពេលវែង ដោយសារគេបានពិចារណាទៅលើស្ថានភាពនិងលក្ខខណ្ឌប្រែប្រួលនានា នៅពេលធ្វើផែនការ។

## ការកសាងផែនការយុទ្ធសាស្ត្រមានប្រយោជន៍អ្វីខ្លះ?

- សំរាប់អោយអង្គការអាចរស់រានមានជីវិតបាន ក្នុងស្ថានភាពមួយដែលមានការប្រែប្រួល។
- ជួយអោយអង្គការបានគិត និងបញ្ជាក់ពីទិសដៅយុទ្ធសាស្ត្ររបស់ខ្លួន។
- ជួយអង្គការកំនត់ និងដោះស្រាយបញ្ហាយុទ្ធសាស្ត្ររបស់ខ្លួន។
- ជួយអង្គការផ្តោតថាមពល ដោយបុគ្គលិកធ្វើការឆ្ពោះទៅគោលដៅតែមួយ។
- ដំណើរការរបស់វា ជួយកសាងក្រុម ដោយសារបុគ្គលិកភាគច្រើនចូលរួមក្នុងដំណើការកសាងផែនការនេះ។
- អង្គការមានផែនការមេមួយដែលអាចប្រើប្រាស់ដើម្បី៖
    - o ធ្វើជាឧបករណ៍គ្រប់គ្រងដើម្បីធ្វើការងារអោយបានល្អ
    - o ធ្វើជាគ្រោងការណ៍សំរាប់រៀបចំផែនការប្រតិបត្តិការ
    - o ធ្វើជាឧបករណ៍សំរាប់ស្វែងរកមូលនិធិ

The article is shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.

# ជំហានក្នុងការកសាងផែនការយុទ្ធសាស្ត្រ

## មុនពេល ធ្វើផែនការ → សិក្ខាសាលា កសាងផែនការ → លទ្ធផលពីការ កសាងផែនការ

### មុនពេល ធ្វើផែនការ

**ត្រៀមលក្ខណ:** (លក្ខខណ្ឌយោង រកអ្នក សំរបសំរួល ទីកន្លែង ជំហាន បង្កើតគណ:កម្មការ រៀបវិភាគ ។ល។)

**ធ្វើអោយបុគ្គលិកមានការយល់ដឹង**ពីផែនការ/ដំណើរការ

**មើលត្រលប់ក្រោយ:** របាយការណ៍វាយតំលៃសិក្ខាសាលាឆ្លុះបញ្ចាំង។

**ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ** (រៀបសំនួរសំភាស/ សួរតាមអ៊ីម៉ែល វិភាគទិន្នន័យ រាយការណ៍ពីលទ្ធផលដល់បុគ្គលិក)។

### សិក្ខាសាលា កសាងផែនការ

- វិភាគស្ថានភាព
- វិភាគតំរូវការ
- កំនត់បញ្ហាយុទ្ធសាស្ត្រ (បញ្ហាអភិវឌ្ឍន៍អង្គការ និងបញ្ហាយុទ្ធសាស្ត្រទាក់ទងនឹងកម្មវិធី)
- បង្កើត/កែសំរួល ទស្សន:វិស័យ បេសកកម្ម គុណតំលៃ។
- បង្កើតគោលបំណងយុទ្ធសាស្ត្រ
- បង្កើតគោលបំណងតាមផ្នែក
- កំនត់សកម្មភាពចំបងៗ និងសូចនាករ។

### លទ្ធផលពីការ កសាងផែនការ

- បញ្ចូលលទ្ធផលពីសិក្ខាសាលាទៅក្នុង**ផែនការពង្រាង**មួយ។
- **ពិភាក្សា/ទទួលយោបល់** លើពង្រាងផែនការ។
- **កែលំអរផែនការ** ជាចុងក្រោយ។
- **បោះពុម្ពនិងចែកចាយ**ផែនការយុទ្ធសាស្ត្រទៅអ្នកពាក់ព័ន្ធ។

**បញ្ជាក់:** ដំណើរការកសាងផែនការយុទ្ធសាស្ត្រដែលល្អ ត្រូវធ្វើឡើងក្នុងកំលុងពេលមួយពី៦ទៅ ១២សប្តាហ៍។ ជាទូទៅគេត្រូវការអ្នកសំរបសំរួលម្នាក់ ឬពីរនាក់ ដើម្បីរៀបចំដំណើរការ និងធ្វើការសំរបសំរួលការគិតរបស់បុគ្គលិក។ ការកសាងផែនការយុទ្ធសាស្ត្រជាដំណើរការរៀនសូត្រមួយ។

The article is shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.